## ព្រះរាជក្រឹត្យ

នស/រកត/០៧១៧/៥៥៦

## ស្ដីពី

## ការកែសម្រួលមាត្រា៦ នៃព្រះរាជក្រឹត្យលេខ នស/រកត/១២៩៩/២២០ ចុះថ្ងៃទី២៧ ខែធ្នូ ឆ្នាំ១៩៩៩ ស្ដីពីការបង្កើតរាជបណ្ឌិត្យសភាកម្ពុជា និងមាត្រា៤ថ្មី, មាត្រា១០ថ្មី, មាត្រា១១ថ្មី, មាត្រា១២ថ្មី និងមាត្រា២០ថ្មី នៃព្រះរាជក្រឹត្យលេខ នស/រកត/០៣០៥/១១១ ចុះថ្ងៃទី០៤ ខែមីនា ឆ្នាំ២០០៥ ស្ដីពីការកែសម្រួលមាត្រា៤ មាត្រា១០ មាត្រា១១ មាត្រា១២ មាត្រា១៤ មាត្រា១៧ និងមាត្រា២០ នៃព្រះរាជក្រឹត្យលេខ នស/រកត/១២៩៩/២២០ ចុះថ្ងៃទី២៧ ខែធ្នូ ឆ្នាំ១៩៩៩ ស្ដីពីការបង្កើតរាជបណ្ឌិត្យសភាកម្ពុជា

## យើង

**ព្រះករុណាព្រះបាទសម្ដេចព្រះបរមនាថ នរោត្ដម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមររដ្ឋរាស្ដ្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្ដិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ដ្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/១២១៣/១៣៩៣ ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១៣ ស្ដីពីការកែសម្រួល និងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៤១៦/៣៦៨ ចុះថ្ងៃទី០៤ ខែមេសា ឆ្នាំ២០១៦ ស្ដីពីការកែសម្រួល និងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/០៩ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការបង្កើតទីស្ដីការគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី ៣០ ខែ តុលា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្ដីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា

ROYAUME du CAMBODGE
LE MINISTRE du PALAIS ROYAL

- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/១២៩៩/២២០ ចុះថ្ងៃទី២៧ ខែធ្នូ ឆ្នាំ១៩៩៩ ស្តីពីការបង្កើតរាជបណ្ឌិត្យសភាកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៣០៥/១១១ ចុះថ្ងៃទី០៤ ខែមីនា ឆ្នាំ២០០៥ ស្តីពីការកែសម្រួលមាត្រា៤ មាត្រា១០ មាត្រា១១ មាត្រា១២ មាត្រា១៤ មាត្រា១៧ និងមាត្រា២០ នៃព្រះរាជក្រឹត្យលេខ នស/រកត/១២៩៩/២២០ ចុះថ្ងៃទី២៧ ខែធ្នូ ឆ្នាំ១៩៩៩ ស្តីពីការបង្កើតរាជបណ្ឌិត្យសភាកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៦១១/៦០០ ចុះថ្ងៃទី២០ ខែមិថុនា ឆ្នាំ២០១១ ស្តីពីការបង្កើតក្រុមប្រឹក្សាជាតិភាសាខ្មែរ
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា

## ត្រាស់បង្គាប់

**មាត្រាមួយ.-**

មាត្រា៦ នៃព្រះរាជក្រឹត្យលេខ នស/រកត/១២៩៩/២២០ ចុះថ្ងៃទី២៧ ខែធ្នូ ឆ្នាំ១៩៩៩ ស្តីពីការបង្កើតរាជបណ្ឌិត្យសភាកម្ពុជា និងមាត្រា៤ថ្មី, មាត្រា១០ថ្មី, មាត្រា១១ថ្មី, មាត្រា១២ថ្មី និងមាត្រា២០ថ្មី នៃព្រះរាជក្រឹត្យ លេខ នស/រកត/០៣០៥/១១១ ចុះថ្ងៃទី០៤ ខែមីនា ឆ្នាំ២០០៥ ស្តីពីការកែសម្រួលមាត្រា៤ មាត្រា១០ មាត្រា១១ មាត្រា១២ មាត្រា១៤ មាត្រា១៧ និងមាត្រា២០ នៃព្រះរាជក្រឹត្យលេខ នស/រកត/១២៩៩/២២០ ចុះថ្ងៃទី២៧ ខែធ្នូ ឆ្នាំ១៩៩៩ ស្តីពីការបង្កើតរាជបណ្ឌិត្យសភាកម្ពុជា ត្រូវបានកែសម្រួល ដូចតទៅ៖

**មាត្រា៤ ថ្មី (មួយ).-**

មាត្រា ៤ ថ្មី កថាខណ្ឌទី១ វាក្យខ័ណ្ឌទី២ ត្រូវបានកែសម្រួលដូចតទៅ៖

សមាជិកពេញសិទ្ធិ មានចំនួនកំណត់មិនលើសពី ៧៩ រូប។

**មាត្រា៦ ថ្មី.-**

លក្ខណៈជាសមាជិកពេញសិទ្ធិ សមាជិកបម្រុង សមាជិកសមាគមិក សមាជិកកិត្តិយស ឬសមាជិកឆ្លើយឆ្លង ត្រូវលោយបាត់ទៅវិញ ដោយមរណភាព ឬដោយការសុំលាឈប់។

សមាជិកពេញសិទ្ធិនៃរាជបណ្ឌិត្យសភាកម្ពុជា រួមគ្នាបង្កើតក្រុមសមាជិកពេញសិទ្ធិ ដែលហៅថា "ក្រុមប្រឹក្សាបណ្ឌិតសភាចារ្យ"។ ការរៀបចំ និងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាបណ្ឌិតសភាចារ្យ ត្រូវកំណត់ដោយព្រះរាជក្រឹត្យ តាមសំណើរបស់នាយករដ្ឋមន្ត្រី។

សមាជិកពេញសិទ្ធិ សមាជិកបម្រុង សមាជិកសមាគមិក សមាជិកកិត្តិយស ឬសមាជិកឆ្លើយឆ្លង ត្រូវបានជ្រើសរើសដោយក្រុមប្រឹក្សាបណ្ឌិតសភាចារ្យ។

លក្ខន្តិកៈសមាជិកនៃរាជបណ្ឌិត្យសភាកម្ពុជា ត្រូវកំណត់ដោយអនុក្រឹត្យ។

**មាត្រា១០ថ្មី(មួយ).-**

រាជបណ្ឌិត្យសភាកម្ពុជាដឹកនាំដោយប្រធាន ០១(មួយ)រូប និងមានអនុប្រធានយ៉ាងច្រើនចំនួន ០៣(បី)រូប ជាជំនួយការ។

ភារកិច្ចរបស់ប្រធាន និងអនុប្រធានរាជបណ្ឌិត្យសភាកម្ពុជា ត្រូវកំណត់ដោយសេចក្តីសម្រេចរបស់ប្រធានរាជបណ្ឌិត្យសភាកម្ពុជា។

**មាត្រា១១ ថ្មី(មួយ).-**

ប្រធាន និងអនុប្រធានរាជបណ្ឌិត្យសភាកម្ពុជា ត្រូវជ្រើសរើសចេញពីក្នុងចំណោមសមាជិកពេញសិទ្ធិ នៃរាជបណ្ឌិត្យសភាកម្ពុជា ហើយត្រូវតែងតាំងដោយព្រះរាជក្រឹត្យ តាមសំណើរបស់នាយករដ្ឋមន្ត្រី។

**មាត្រា១២ ថ្មី(មួយ).-**

អគ្គលេខាធិការដ្ឋាននៃរាជបណ្ឌិត្យសភាកម្ពុជា ដឹកនាំដោយអគ្គលេខាធិការ ០១ (មួយ) រូប និងអគ្គលេខាធិការរង យ៉ាងច្រើនចំនួន ០៣(បី) រូប ដើម្បីជួយការងារប្រធានរាជបណ្ឌិត្យសភាកម្ពុជា។

អគ្គលេខាធិការ ត្រូវមានសញ្ញាបត្របណ្ឌិត និងត្រូវតែងតាំងដោយព្រះរាជក្រឹត្យ មានឋានៈស្មើ រដ្ឋលេខាធិការ។

អគ្គលេខាធិការរង ត្រូវមានសញ្ញាបត្របរិញ្ញាបត្រជាន់ខ្ពស់ឡើងទៅ និងត្រូវតែងតាំងដោយព្រះរាជក្រឹត្យ មានឋានៈស្មើ អនុរដ្ឋលេខាធិការ។

ការបែងចែងភារកិច្ចអគ្គលេខាធិការ និងអគ្គលេខាធិការរង ត្រូវកំណត់ដោយសេចក្តីសម្រេចរបស់ប្រធានរាជបណ្ឌិត្យសភាកម្ពុជា។

**មាត្រា២០ថ្មី(មួយ).-**

រាជបណ្ឌិត្យសភាកម្ពុជា មានវិទ្យាស្ថាន និងស្ថាប័នឧបសម្ព័ន្ធដូចខាងក្រោម ៖

១- វិទ្យាស្ថានវប្បធម៌ និងវិចិត្រសិល្បៈ

២- វិទ្យាស្ថានមនុស្សសាស្ត្រ និងវិទ្យាសាស្ត្រសង្គម

៣- វិទ្យាស្ថានជីវសាស្ត្រ វេជ្ជសាស្ត្រ និងកសិកម្ម

៤- វិទ្យាស្ថានវិទ្យាសាស្ត្រ និងបច្ចេកវិទ្យា

៥- វិទ្យាស្ថានភាសាជាតិ

៦- វិទ្យាស្ថានទំនាក់ទំនងអន្តរជាតិកម្ពុជា

៧-ឧទ្យានរាជបណ្ឌិត្យសភាកម្ពុជា តេជោសែន ឫស្សីត្រើប។

រាជបណ្ឌិត្យសភាកម្ពុជា អាចបង្កើតវិទ្យាស្ថាន និងស្ថាប័នឧបសម្ព័ន្ធផ្សេងទៀតតាមការចាំបាច់ដោយអនុក្រឹត្យ។

**មាត្រាពីរ.-**

ត្រូវរៀបចំផ្ទេរតាមរយៈព្រះរាជក្រឹត្យនូវក្រុមប្រឹក្សាជាតិភាសាខ្មែរ ដែលត្រូវបានបង្កើតឡើងដោយព្រះរាជក្រឹត្យលេខ នស/រកត/០៦១១/៦០០ ចុះថ្ងៃទី២០ ខែមិថុនា ឆ្នាំ២០១១ ឱ្យស្ថិតនៅក្រោមសមត្ថកិច្ច និងការទទួលខុសត្រូវរបស់រាជបណ្ឌិត្យសភាកម្ពុជា។

**មាត្រាបី.-**

លិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធនឹងកិច្ចដំណើរការរបស់រាជបណ្ឌិត្យសភាកម្ពុជា ដែលកំពុងអនុវត្តត្រូវបន្តអានុភាពអនុវត្តរហូតដល់មានលិខិតបទដ្ឋានថ្មី មកជំនួស។

បទប្បញ្ញត្តិទាំងឡាយណា ដែលផ្ទុយនឹងព្រះរាជក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

ROYAUME DU CAMBODGE
LE MINISTRE DU PALAIS ROYAL

មាត្រាបួន.-

សម្ដេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី២៩ ខែកក្កដា ឆ្នាំ ២០១៧

**ក្នុងព្រះបរមនាម និងតាមព្រះរាជត្រាស់បង្គាប់**

**ប្រមុខរដ្ឋស្ដីទី**

**ហត្ថលេខា និងព្រះរាជលញ្ឆករ**

ចរស.១៧០៧.៥៩៥

**សម្ដេចវិបុលសេនាភក្ដី សាយ ឈុំ**

បានយកសេចក្ដីក្រាបបង្គំទូលថ្វាយព្រះមហាក្សត្រ

សូមឡាយព្រះហស្តលេខា

**នាយករដ្ឋមន្ត្រី**

**ហត្ថលេខា**

**សម្ដេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

លេខៈ ៥៩២ ស.ណ

**សំណៅដែលមានតម្លៃជាការចែកផ្សាយ**

រាជធានីភ្នំពេញ ថ្ងៃទី ៣១ ខែកក្កដា ឆ្នាំ២០១៧

**អគ្គលេខាធិការរាជរដ្ឋាភិបាល**

**សុយ សុខា**